# មិនសាកមិនដឹង

គេតែងថាធ្វើកិច្ចការតោងអំណត់
ឱ្យតែស៊ូទោះឆាប់យូរឆ្លងឧបសគ្គ
ទឹកតក់ៗច្រើនតំណក់ស្រក់ដាច់ថ្ម
មួយជំហាន! មួយជំហាន! ជាច្រើនដង
មានព្យាយាមមិនទីមទាមប្រសើរហើយ
ខ្ញុំថាមនុស្សគួរតែចេះត្រិះប្រមាណ
មានឱហាតត្រូវឈ្លាសឆ្លាតផ្សែផ្សំផង
ដូចទន្សាយខំរាំថ្វាយព្រះច័ន្ទថ្លៃ
អ្នកខ្លះប្រឹងរឹងជំនះដើរផ្លូវមួយ
ម្ដេចមិនបែររេរកផ្លូវផ្សេងវិញណា
ការជ្រើសផ្លូវអាចមានត្រូវអាចមានខុស
បើមិនសាកក៏មិនដឹងប្រាកដណាស់

ចេះអត់ធ្មត់នោះប្រាកដជោគជ័យជាក់
គង់តែអ្នកសម្រេចជាក់ដូចបំណង។
ដែកដុលល្អក៏អាចដុសជាម្ជុលផង
អ្នកអាចឆ្លងដងមាត់វែងឆ្ងាយបាន។
តែនៅឡើយពុំទាន់គ្រប់សព្វលំអាន
ស្ទាបស្ទង់ស្មានដឹងដើមដានទើបប្រពៃ។
ការខ្លះប៉ងធំហួសមាឌឃ្លាតជោគជ័យ
រាំដល់ក្ស័យក៏គ្មានថ្ងៃច័ន្ទមេត្តា។
រងទុក្ខព្រួយដួលញយៗជាន់បន្លា
ក្រែងអាត្មារួចទុក្ខាវាសនាផ្លាស់។
កើតជាមនុស្សម្ដេចនឹងដឹងថ្ងៃមុខច្បាស់
ថ្មីឬចាស់ទុកឬផ្លាស់ស្រេចអ្នកហោង៕

**ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រាសិរី**

